សិលាចារឹកពើងគំនូរ K.176

ពើងគំនូរ មានទីតាំងស្ថិតនៅភូមិត្រពាំងទឹម ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប (រូបលេខ១)។ ទីតាំងនេះ មានសិលាចារឹកចំនួនពីរផ្ទាំង ដែលស្ថិតនៅក្បែរគ្នាតែម្តង។ សិលាចារឹកទី១ ចារឹកជាភាសាខ្មែរ ចារនៅត្រង់ផ្នែកខាងលើចម្លាក់ឥសីម្នាក់ដែលកំពុងអង្គុយក្នុងឥរិយាបថយោគិសន និងមានភ្នួងសក់ផង ដោយបង្ហាញតែមួយបន្ទាត់ប៉ុណ្ណោះ សរសេរថា "វ្រះសិវសោម" (ឈ្មោះរបស់ព្រះរាជគ្រូ)។ សិលាចារឹកមួយទៀត ចារឹកជាភាសាសំស្ក្រឹត មានចំនួន ១៦បន្ទាត់ ដែលធ្លាប់សិក្សានិងបកប្រែពីសំស្ក្រឹតទៅជាបារាំងដោយលោក ហ្សក សឺដេស ម្តងរួចមកហើយ ប៉ុន្តែលោកហៅឈ្មោះសិលាចារឹកនេះថា ពើងកេងកង ទៅវិញ។

អត្ថន័យសង្ខេបរបស់សិលាចារឹកនេះ រៀបរាប់សរសើរអំពីគុណលក្ខណៈរបស់ព្រាហ្មណ៍ម្នាក់ឈ្មោះ "សិវសោម" ដែលជាព្រះរាជគ្រូរបស់ព្រះបាទស្រីន្ទ្រវម៌្មទេវ (ឥន្ទ្រវរ្ម័នទី១) សោយរាជ្យសម្បត្តិនៅនគរហរិហរាល័យ នៅចុងស.វ.ទី៩ (គ.ស.៨៧៧ ដល់ ៨៨៩)។ ប៉ុន្តែ សិលាចារឹកនេះពុំមែនចារនៅស.វ.ទី៩ ដំណាលពេលនៃសាច់រឿងដែលបានរៀបរាប់នោះទេ ពោល គឺចារនៅមហាសករាជឆ្នាំ៩៩៦ ត្រូវនឹងគ្រឹស្តសករាជឆ្នាំ១០៧៤ (ចុងស.វ.ទី១១)។ តាមរយៈសំណេររបស់សិលាចារឹក យើងអាចដឹងព័ត៌មានច្រើនអំពីពើងថ្មនេះ ជាក់ស្តែងនៅសម័យបុរាណកាលគេហៅពើងនេះថា "មហេន្ទ្រគុហា"។ ព័ត៌មានបន្ថែមទៀតនោះគេបានបញ្ជាក់ថា "រូងគុហានេះស្ថិតនៅត្រង់ចង្កេះភ្នំមហេន្ទ្របព៌ត" (មហេន្ទ្របព៌ត ជាឈ្មោះបុរាណរបស់ភ្នំគូលែន)។ អ្វីដែលគួរកត់សម្គាល់នោះ គឺរូបចម្លាក់របស់ព្រាហ្មណ៍សិវសោម ក៏បានឆ្លាក់ទុកនៅលើជញ្ជាំងថ្មពើងគំនូរនេះដែរ (រូបលេខ២)។

យោងទៅតាមគម្ពីរវុត្តរត្នាករ កំណាព្យសំស្ក្រឹតស្លោកទី១របស់សិលាចារឹកពើងគំនូរជាប្រភេទ "អតិធ្ឫតឆន្ទ" ដែលមានចំនួន ១៩ ព្យាង្គ មានឈ្មោះថា "គាទ៌ូលវិក្រិឌិកា / គាទ៌ូលលិតា ប្រកបដោយ ម,ស,ជ,ស,ត,ត,គ។ ស្លោកទី២ ជាប្រភេទ "ប្រក្ឫតិឆន្ទ" មានចំនួន ២១ ព្យាង្គ មានឈ្មោះថា "ស្រគ្ធរា" ប្រកបដោយ ម -រ -ភ -ន -យ -យ -យ -យ។ ស្លោកទី៣ ជាប្រភេទ "អនុស្តុភ៌" ដែលជាកំណាព្យគេនិយមតាក់តែងខ្លាំងនៅសម័យបុរាណខ្មែរ ដ្បិតវាមានភាពងាយស្រួលក្នុងការនិពន្ធទៀតផង។ អនុស្តុភ ជាប្រភេទមេកាព្យមួយប្រភេទដែលចែកជាច្រើនប្រភេទ ដោយកំណត់ចំណាំងាយជាងគេបំផុតគឺនៅត្រង់គ្រាប់ព្យាង្គទី៥ទាំងអស់របស់បាទ ត្រូវតែជាព្យាង្គ "លឃុ" (សំឡេងស្រាល) ព្យាង្គទី៧របស់បាទទី២និងទី៤ ជាព្យាង្គ "គរុ" (សំឡេងធ្ងន់វែង)។ ស្លោកទី៤ ជាប្រភេទ "ត្រិស្តុភឆន្ទ" មានឈ្មោះថា "ឧបជាតិ" ដែលឆន្ទនេះកើតឡើងពីការបន្សំរវាងឥន្ទវជ្រា និងឧបេន្ទ្រវជ្រា។ ស្លោកទី៥ និងទី៦ ជាប្រភេទអយ៉ាឆន្ទ (មាតាវុត្ត)។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

អត្ថបទពាក្យចារឹក

១. **គាកេ មណ្ឌវរន្ធ្រកេ សហ គណៃរ ទេវា មហេគាទយោ**
ទេវ្យគិ គៃលសុតាទយគិ ច គិវសោមាខ្យេន សម្យង្ធ្យា
មហេន្ទ្រាទ្រិគុហាតដេមុ វិធិនា សំស្ថាបិតាសិ តាគិ ច តេ
ទេយាសុរិ មុនយេ តបស្យត ឥហ ស្វគាំបវគៅ សទា ។

ប្រែថា៖ *ក្នុងឆ្នាំសក. ដែលកំណត់ដោយ រន្ធ=៩ នវ=៩ និង៦ =៩៩៦សក. ព្រះជាអម្ចាស់ (ទេវ) មានព្រះបរមនាមផ្ដើមដោយពាក្យថា "មហេស" ទេវគណៈរបស់ទ្រង់ ព្រមទាំងព្រះទេវី (អគ្គទេពី) ជារាជបុត្រីរបស់ស្ដេចភ្នំ (ហិមាលយ) បានសាងឡើងតាមក្បួនតម្រាសាស្ត្រ ដោយខ្ញុំម្ចាស់មាននាមថា "សិវសោម" នៅត្រង់ចង្កេះគុហាភ្នំស្រីមហេន្ទ្របព៌តនេះ។ សូមឱ្យ ព្រះមហេស្វរ និងព្រះនាង បារ្វតី ជួយតាមឃុំគ្រងថែរក្សា ដោយការប្រោសប្រទាននូវមេឃ ដើម្បីជួយទ្រទ្រង់នូវកិច្ចប្រតិបត្តិ តបៈនៅត្រង់ទីនេះរហូតតរៀងទៅ។*

២. **យគ្វាខ្យាំ សោមនិឞ្ឋាំ សុកតបសិ យមី សំយតាត្មា គិវាទិ**
ក្វត្សានានេ្ធវហ្និទ្វិជគុរុជគតាន្តបំកោ កៃក្បគោត្បែះ
អាត្មីយន្និត្យកម្មាន្តុតមសមមិវាទគំយន្ធេវមាទ្យា
ន្ធេវីទីប្រាសុរទ្វិជ្ជ្យថមមខកុជាមត្រ រូបាណិ ចក្រេ ។

ប្រែថា៖ *ព្រាហ្មណ៍នោះបានអប់រំខ្លួន ដោយការធ្វើតបធម៌ដ៏បរិសុទ្ធិ អាចយកឈ្នះលើអាត្ម័នរបស់ខ្លួនឯង មានចិត្តជ្រះថ្លាបរិសុទ្ធជាមួយនឹងព្រះ ព្រះអគ្និ (ភ្លើង), ព្រាហ្មណ៍, គ្រូ និងពពួកសត្វនិករទាំងឡាយដោយគ្មានចិត្តលំអៀង ចិញ្ចឹមជីវិតដោយទ្រព្យសម្បត្តិ មានការបរិច្ចាគទាន គាត់មាននាមខាងចុងដោយពាក្យថា* ***សោម*** *និងផ្ដើមដោយពាក្យថា* ***សិវ***។ *គាត់បានបំពេញកាតព្វកិច្ចដ៏អស្ចារ្យដោយខ្លួនឯង ហើយគ្មាននរណាអាចប្រដូចបាន។ ព្រះតេជព្រះគុណ សិវសោម បានកសាងនូវទេវបដិមា ទេវី អគ្និ វិស្ណុ ដែលជាសត្រូវជាមួយពួកអសុរៈ និងបានសាងបដិមាព្រះសិវ ដែលបានទទួលតង្វាយជាបឋម។*

៣. **យន្ធេវគៃលសំស្ថាយី តបស្វី វហុបុណ្យកះ**
កៃក្បគី គិវសោមាខ្យា ស្បោការយទិមា និមាះ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

ប្រែថា៖ គាត់ជាតាបស បានអាស្រ័យនៅលើភ្នំ ឧទ្ទិសខ្លួនថ្វាយជាសាវ័កព្រះសិវៈ ជាអ្នកបានតាក់តែងសម្រង់អត្ថបទ ជាអ្នកមានបុណ្យច្រើន ហើយជាអ្នកចិញ្ចឹមជីវិត មានប្រក្រតីដោយការបរិច្ចាគទាន ហើយគាត់មាននាមថា សិវសោម លោកបានកសាងទេវបដិមានៅត្រង់ទីកន្លែងនេះ។

៤. **សវិព្ណុវសស្យគណាត្ស សោមះ ផលំ ប្រទាតុំ គិវសោមនាម្នេ**
តបស្យតេ នាកសមេ មហេន្ទ្រ សានៅ គុហាយាមនិគន្និតស្តៅ។

ប្រែថា៖ ព្រះឦស ព្រះវិស្ណុ ព្រះសោម ជាមួយនិងទេវពលបរិវារ បានថ្វាយពរសព្វសាធុការដល់តាបសមាននាមថា **សិវសោម** មានប្រក្រតីអាស្រ័យនៅក្នុងគុហា លើកំពូលភ្នំស្រីមហេន្ទ្របព៌ត ដែលប្រដូចបានទៅនឹងស្ថានសួគ៌ាល័យ។

៥. **គិវសោមមុនិម៌តិមា ន្មានេ្យា យមិនាំ យមី គុហាវាសី**
ភគវត្បាទាមរនោ ទាជុំនជដិលោ បិង្គាវារី។

ប្រែថា៖ ព្រះតេជព្រះគុណ សិវសោម ប្រកបដោយប្រាជ្ញាវាងវៃ ជាអ្នកសមនឹងទទួលបាននូវការគោរពពីអ្នករាល់គ្នា អ្នកទទួលមានជោគជ័យលើអារម្មណ៍របស់ខ្លួន ជាអ្នកឈ្នះលើខ្លួនឯង។ គាត់ជាអ្នកមានប្រក្រតីដោយការរស់នៅ អាស្រ័យព្រះគុហាជាទីពុំនាក់ គាត់មានក្អួសក់ពណ៌ស និងស្បៀកដណ្តប់ដោយសំពត់ពណ៌លឿង។

៦. **សច្ចិលវពោ យោគេ្យា យោគាក្យាសោ តិយោគវិន្ទមិតះ**
អស្យាមេតាះ ប្រតិមាះ បរមេឝ្វរភក្តយេ ក្ឫតវានិ ។

ប្រែថា៖ គាត់ជាកំពូលមនុស្ស លើមនុស្សទាំងពួង មានសមត្ថភាពខាងធ្វើតបៈ និងយោគៈ ជាអ្នកមានចំណេះដឹងខ្ពស់មានប្រក្រតីជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឱនលំទោន ជាអ្នកកសាងទេវបដិមាក្នុងរូងគុហានេះ ដើម្បីសម្រាប់ជាការគោរពបូជាដល់ព្រះបរមេស្វរ។

ជារួមមក សិលាចារឹកពើងគំនូរដែលបានរៀបរាប់ខាងលើនេះ រំលេចឃើញអំពីព័ត៌មានសំខាន់ខាងផ្នែកអក្សរសាស្ត្រ និងភាសាសាស្ត្រ ដែលរំលេចឱ្យឃើញអំពីការបរិច្ឆេទជាក់លាក់នៃការតែងនិពន្ធ។ ជាពិសេសនោះ គឺបញ្ជាក់អំពីតួអង្គដែលមាននៅក្នុងប្រវត្តិសាស្ត្រពិត ពោល គឺព្រាហ្មណ៍ដ៏សំខាន់ម្នាក់ឈ្មោះថា "សិវសោម" ដែលបានបម្រើស្តេចឥន្ទ្រវរ្ម័នទី១ នៅចុងស.វ.ទី៩។ លើសពីនេះ ព័ត៌មានរបស់សិលាចារឹកក៏បានឱ្យយើងយល់ដឹងអំពីតួនាទីរបស់ព្រាហ្មណ៍នេះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

កាន់តែច្បាស់បន្ថែមទៀត។ ម្យ៉ាងវិញទៀត សិលាចារឹកនេះក៏បានឱ្យយើងស្គាល់ឈ្មោះបុរាណ របស់ភ្នំគូលែន ពោល គឺបុរាណកាលគេហៅថា "មហេន្ទ្របព៌ត" ហើយគុហាដែលយើងហៅថា "ពើងគំនូរ" នោះ មានឈ្មោះថា "មហេន្ទ្រគុហា"។

ឯកសារយោង

Coedès, G.
1953, *Inscription du Cambodge*, Vol V, Hanoi.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១៖ ចម្លាក់ទេពនិករផ្សេងៗក្នុងព្រហ្មញ្ញសាសនានៅពើងគំនូរ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

រូបលេខ២៖ ចម្លាក់រូបព្រាហ្មណ៍សិវសោម នៅពើងគំនូរ

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ សិលាចារឹកពើងគំនូរ

KHMER CIVILIZATION



រូបលេខ២៤៖ ក្រដាសផ្តាមសិលាចារឹកពើធ៍គំនូរ (ផ្ដិតដោយ៖ កំ វណ្ណារ៉ា)

KHMER CIVILIZATION